ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ០៧៣៨ ព.ណ.កសសរ

ភ្នំពេញ, ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកត់ត្រាទទួលស្គាល់កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងម្ចាស់ម៉ាកទាំងអស់ឲ្យបានជ្រាបថា អនុលោមតាមមាត្រា ១៩ និងមាត្រា ៥២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងមាត្រា ២៧(៣) នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ រាល់ការដាក់ពាក្យស្នើសុំកត់ត្រាទទួលស្គាល់កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ (License Contract) ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស (Franchise Contract) ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ដូចមានគំរូពាក្យស្នើសុំជូនភ្ជាប់ ។ អ្នកស្នើសុំ ត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេសជាច្បាប់ដើម និងអមដោយអត្ថបទបកប្រែជាភាសាខ្មែរ ដែលត្រូវបញ្ជាក់ពីភាពត្រឹមត្រូវលើការបកប្រែទាំងនោះដោយភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬអង្គភាពវិជ្ជាជីវៈបកប្រែដែលទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមសាធារណជន និងម្ចាស់ម៉ាកទាំងអស់ ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation - Religion - King**

គំរូទំរង់លេខ: ០៣៧
Form: 037-RRL/FC-Eng
កម្ពុជា *CAMBODIA*

*ជូនចំពោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម*
*(To: Department of Intellectual Property, Ministry of Commerce)*

# ពាក្យស្នើសុំកត់ត្រាកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស
## *REQUEST FOR RECORDAL OF LICENSE CONTRACT/FRANCHISE CONTRACT*

១ - ម៉ាក (Mark):

២ - ជំពូក (Class):

៣ - លេខដាក់ពាក្យ (Application Number):

៤ - លេខចុះបញ្ជីដើម (Original Registration Number):

៥ - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្តល់អាជ្ញាប័ណ្ណ (Name and Address of Licensor/Franchisor): ________________
________________________________________________________________

៦ - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ (Name and Address of Licensee/Franchisee): ________________
________________________________________________________________

៧ - ឈ្មោះរបស់ភ្នាក់ងារ/មេធាវី តំណាងក្នុងស្រុក និងអាសយដ្ឋានសំរាប់ទំនាក់ទំនង (Name of Local Agent/Attorney and Address for Service): ________________________________________________
________________________________________________________________

ទូរស័ព្ទ (Tel):________________ ទូរសារ (Fax):________________ អ៊ីម៉ែល (Email)________________________

៨ - ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ (Documents Accompanying the Application):

- កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេសច្បាប់ដើម ឬច្បាប់ចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ (Original License/Franchise Contract or Notarized Copy thereof)
- ការបកប្រែកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស ពីភាសាអង់គ្លេស ទៅភាសាខ្មែរ (Translation of License/Franchise Contract from English to Khmer)
- លិខិតប្រគល់សិទ្ធិ និងលិខិតប្រគល់សិទ្ធិបន្តច្បាប់ដើម ប្រសិនបើភ្នាក់ងារ/មេធាវី តំណាងត្រូវបានជ្រើសតាំងថ្មី (Original Notarized Power of Attorney and Deed of Substitution, if the Agent/Attorney is newly appointed)
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកដើមថតចម្លង ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីថតចម្លង (A Copy of Principal Mark Registration or Renewal Certificate)

ហត្ថលេខា និងត្រា (Signature and Stamp): ________________________

ឈ្មោះហត្ថលេខី (Name of Signatory): ________________________

មុខងារ (Title):________________________

កាលបរិច្ឆេទ (Date): ________________________